THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
Superintendent

ជូនចំពោះសហគមន៍ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

តាមការពិចារណាព្រឹត្តិការណ៍ថ្មីៗ ខ្ញុំសូមចែករំលែកសារនេះ នៅថ្ងៃនេះ ដើម្បីបញ្ជាក់ឡើងវិញនូវការប្តេជ្ញារបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ក្នុងការបង្កើតកន្លែងដែលមានសុវត្ថិភាព និងមានការស្វាគមន៍សម្រាប់សិស្ស និងក្រុមគ្រួសាររបស់យើង ដែលស្របតាមរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ច្បាប់រដ្ឋ Pennsylvania និងក្នុងស្មារតីនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអប់រំ ថាសាលាជាទីកន្លែងដែលមានការស្វាគមន៍។ នេះរួមបញ្ចូលសិស្សទាំងអស់ មិនគិតពីពូជសាសន៍ ជាតិព័ន្ធ ស្ថានភាពអន្តោប្រវេសន៍ ដើមកំណើត ភេទដែលចេញពីអារម្មណ៍របស់ខ្លួន និងការបង្ហាញឱ្យឃើញពីភេទរបស់ខ្លួន ទំនោរនៃសេចក្តីស្រឡាញ់ ស្ថានភាពគ្រួសារ សាសនា ឬសមត្ថភាពរបស់អ្នកនោះទេ។ ក្រសួងអប់រំនឹងធ្វើតាមច្បាប់ដែលបានតម្រូវ ហើយក្រុមអ្នកដឹកនាំសាលាត្រូវបានផ្តល់ការណែនាំអំពីវិធីការពារសិទ្ធិរបស់សិស្សអន្តោប្រវេសន៍របស់យើង។

**អ្វីៗដែលសិស្ស និងក្រុមគ្រួសារត្រូវដឹង៖**

- សូមប្រាកដថាព័ត៌មានសម្រាប់ទាក់ទងនៅពេលមានអាសន្នទាំងអស់សម្រាប់សិស្សរបស់លោកអ្នកមានព័ត៌មានថ្មីៗដែលអាចទាក់ទងបាន។ ដើម្បីផ្តល់ព័ត៌មានថ្មីៗរបស់លោកអ្នកសម្រាប់ទាក់ទង សូមទាក់ទងសាលារបស់កូនលោកអ្នក។
- បុគ្គលិក អ្នកស្ម័គ្រចិត្ត និងអ្នកម៉ៅការ ត្រូវបានហាមឃាត់មិនឱ្យសួរអំពី ឬចែករំលែកព័ត៌មានផ្ទាល់ខ្លួនអ្វីមួយអំពីសិស្ស ឬក្រុមគ្រួសាររបស់លោកអ្នក រួមទាំងស្ថានភាពអន្តោប្រវេសន៍ លុះត្រាតែតម្រូវដោយច្បាប់ និងមានការអនុញ្ញាតពីការិយាល័យអគ្គមេធាវីរបស់ក្រសួងអប់រំ។
- យើងបានផ្តល់ការណែនាំដល់ក្រុមអ្នកដឹកនាំសាលាអំពីវិធីដោះស្រាយនៅពេលមានសំណើអ្វីមួយពីមន្ត្រីអន្តោប្រវេសន៍។

ប្រសិនបើលោកអ្នកមានសំណួរ ឬការបារម្ភអ្វី សូមទាក់ទងមកយើងខ្ញុំដោយប្រើវេទិកាទំនាក់ទំនងទៅវិញទៅមករបស់យើង ដោយចុចលើពាក្យអង់គ្លេសពណ៌ខៀវនេះ Let’s Talk ។ យើងនឹងបន្តធ្វើការក្នុងការផ្តល់ព័ត៌មានដ៏មានន័យ និងការហ្វឹកហ្វឺនដ៏សំខាន់ដល់បុគ្គលិកសាលា និងបុគ្គលិកក្រសួងអប់រំ ដើម្បីបង្កើតបរិយាកាសដែលមានសុវត្ថិភាព និងមានការស្វាគមន៍ ដែលសិស្សទាំងអស់របស់យើងអាចរៀនសូត្រ និងរីកចម្រើន។

ក្នុងភាពជាដៃគូ

Tony

Tony B. Watlington Sr., Ed.D.
អគ្គនាយកនៃក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា